ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d’appui aux victims**

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០

**<u>សេចក្តីប្រកាសព័ត៌មាន</u>**

# អង្គភាពគាំពារជនរងគ្រោះរៀបចំការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ជនបង្គោលមកពីបណ្តាខេត្តចំនួន ២១ សម្រាប់យកទៅបណ្តុះបណ្តាលបន្តដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ (VSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ជនបង្គោលចំនួន ១២០ នាក់មកពីខេត្តផ្សេងៗចំនួន ២១ នៃព្រះរាជាណាចក្រកម្ពុជានៅ**ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ នៅសណ្ឋាគារ Hotel Imperial Garden Phnom Penh Hotel ចាប់ពីម៉ោង ៨:00 ព្រឹក។**

ការបណ្តុះបណ្តាលនេះមានគោលបំណងជួយឲ្យជនបង្គោលដែលបានជ្រើសរើស អាចទទួលព័ត៌មានត្រឹមត្រូវ ទាន់ហេតុការណ៍ពីអង្គភាពគាំពារជនរងគ្រោះ និងចែករំលែកយ៉ាងមានប្រសិទ្ធភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតក្នុងសំណុំរឿង ០០២។

កម្មវិធីបណ្តុះបណ្តាលនេះផ្តល់ឱកាសដល់ជនបង្គោលក្នុងការជួបជាមួយមន្ត្រីពីបណ្តាការិយាល័យនានានៅ អ.វ.ត.ក និងមន្ត្រីសង្គមស៊ីវិល។ តាមរយៈការបណ្តុះបណ្តាលនេះ ជនបង្គោលនឹងបង្កើនចំណេះដឹងរបស់ខ្លួនអំពីកិច្ចដំណើរការនីតិវិធីដែលកំពុងបន្ត និងបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។ គោលបំណងនៃការបណ្តុះបណ្តាលនេះគឺដើម្បីធានាថា ជនបង្គោលនឹងមាន



Original EN: 01704412-01704412

សមត្ថភាពក្នុងការរៀបចំការបណ្តុះបណ្តាលបន្ត ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតនៅក្នុងសហគមន៍/ខេត្តរបស់ខ្លួន នៅទូទាំងប្រទេស។

នេះជាការបណ្តុះបណ្តាលជនបង្គោលក្រុមទីពីរ។ អង្គភាពគាំពារជនរងគ្រោះបានរៀបចំការបណ្តុះបណ្តាលគ្រូបង្គោលជុំទីមួយសម្រាប់ជនបង្គោលកាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**លោក អ៊ឹម សុភា**មន្ត្រីសម្របសម្រួលការផ្សព្វផ្សាយ ទូរស័ព្ទ៖ ០៧៧ ៧៧៧ ៣៦៧, អ៊ីមែល៖ im.sophea@eccc.gov.kh



Original EN: 01704412-01704412